# ផ្លែក្រូច ម្ដងមួយផ្លែ



ដោយ ស៊ីស្ទើរ សារ៉ុន អ៊ូបែង
ទីប្រឹក្សាទីមួយនៅក្នុងគណៈប្រធានសមាគមសង្គ្រោះទូទៅ



កាលខ្ញុំនៅក្មេង ឪពុកម្ដាយខ្ញុំបាននាំបងស្រីខ្ញុំ និងខ្ញុំទៅចម្ការមួយដែលជារបស់សាសនាចក្រ ។ យើងទៅទីនោះដើម្បីជួយបេះផ្លែក្រូច ។ យើងបានឡើងជណ្ដើរដ៏ខ្ពស់ ហើយឈោងដៃតាមស្លឹកឈើក្រាស់ៗដើម្បីបេះផ្លែក្រូចពីដើម ។

ដំបូងឡើយ យើងមានចិត្តរំភើប ។ ប៉ុន្តែរំពេចនោះ រោមនៅលើផ្លែក្រូចនោះបានធ្វើឲ្យដៃយើងរមាស់ ! យើងបានប្រាប់ម៉ាក់ថា « កូនមិនចង់ធ្វើកិច្ចការនេះទៀតទេ ។ កូនចង់ឈប់ហើយ » ។



ម្ដាយខ្ញុំបានសួរថាតើយើងដឹងពីកន្លែងដែលគេយកផ្លែក្រូចទាំងអស់ទៅដែរឬទេ ។ ពេលយើងនិយាយថាទេ គាត់បានពន្យល់យើង ។

« ផ្លែក្រូចទាំងនេះត្រូវយកទៅកាន់អគារមួយដែលពួកអ្នកស្ម័គ្រចិត្តដាក់វានៅក្នុងកំប៉ុង ។ បន្ទាប់មកកំប៉ុងទាំងនោះត្រូវបានផ្ដល់ឲ្យទៅមនុស្សដែលត្រូវការអាហារ ។ រៀងរាល់ឆ្នាំសាសនាចក្របរិច្ចាគអាហាររាប់ពាន់កំប៉ុង » ។

ស្រាប់តែពេលនោះ បងស្រីខ្ញុំ និងខ្ញុំបានឈប់ខ្វល់ពីការរមាស់ដៃរបស់យើង ។ យើងកំពុងជួយមនុស្សដែលត្រូវការអាហារ ! បន្ទាប់ពីនោះ យើងមានចិត្តរីករាយដើម្បីឡើងលើជណ្ដើរដើម្បីបេះផ្លែពណ៌ទឹកក្រូចដែលមានរោមនោះ ។

ឆ្នាំនេះយើងបានសូមអ្នកឲ្យចូលរួមនៅក្នុងការអញ្ជើញនៃដៃជំនួយ ( សូមមើលទស្សនាវដ្ដី *ប្រិយមិត្ត*ខែមករា ឆ្នាំ២០២១ ) ។ ការបម្រើមនុស្សដទៃតាមរបៀបដែលព្រះគ្រីស្ទបានបម្រើគឺជារឿងដ៏សំខាន់បំផុតមួយដែលអ្នកអាចធ្វើ ។ កុមារមានរបៀបពិសេសមួយក្នុងការកត់សម្គាល់ឃើញមនុស្សដែលខ្វះខាត ហើយស្ម័គ្រចិត្តផ្ដល់ជំនួយ ។ ទង្វើនៃការបម្រើដ៏តូចមួយ ទំនងជាមិនធ្វើឲ្យមានភាពខុសប្លែកច្រើននោះទេ ។ ប៉ុន្តែបើកុមារគ្រប់រូបជុំវិញពិភពលោកស្វែងរកវិធីដើម្បីបម្រើ នោះពួកគេនឹងបង្កើតជារឿងដ៏អស្ចារ្យ ! ●

*ដកស្រង់មកពីការសម្ភាសមួយជាមួយ អែមបើរ ហ៊ីលី ។*

សូមផ្ញើមកកាន់យើងនូវដំណើររឿងមួយអំពីរបៀបដែលអ្នកជួយមនុស្សដទៃនៅកន្លែងដែលអ្នករស់នៅ ! សូមមើលក្របខាងក្រោយដើម្បីដឹងពីរបៀប ។

